This project

is co-funded by:

actionaid

# សមាគមអភិវឌ្ឍន៍បង្កើនសេដ្ឋកិច្ចគ្រួសារ

## ASSOCIATION FOR DEVELOPMENT INCREASE

## THE FAMILY ECONOMICS, ADIFE

**phone;** 044 399 037 / 016 705 464

## Report of field coaching with ADIFE

Respective CNFSC core representative from RFCD conducted 4 days field coaching and agriculture training to extended farmers in Svay Rieng province where is the target areas of CNFSC member, ADIFE. The field coaching and agriculture training focused on reviewing the trained agriculture techniques and added some newly techniques. This was covered for 47 farmers, 12 women.

# របាយការណ៍
# ស្តីពី
# ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនិរន្តរភាពដល់ក្រុមកសិករ

កាលពីថ្ងៃទី ១៥-១៨ ខែឧសភាឆ្នាំ ២០១១ : អេឌីសបានសហការជាមួយកសិករគំរូដែលមានបទពិសោធន៏មកពីអង្គការ RFCD រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនិរន្តរភាពចំនួន ២វគ្គ រយៈពេល ៤ថ្ងៃ ដល់ប្រធានក្រុមកសិករចំនួន ៤៧នាក់ ស្ត្រី ១២នាក់ មកពី ១៨ភូមិ នៅការិយាល័យអេឌីស ដើម្បីបង្កើនជំនាញ កសិកម្មដល់ពួកគេ ដោយផ្តោត ទៅលើបច្ចេកទេសចិញ្ចឹមមាន់ ត្រី វិធីធ្វើជីកំប៉ុស្តិ៍ទឹក-គោក វិធីបន្សុតជីកំប៉ុស្តិ៍អោយ ក្លាយជាជីប្រភេទលេខ១ និង វិធីធ្វើថ្នាំបណ្តេញសត្វល្អិតដែលផ្សំពីរុក្ខជាតិ។ ហើយក្នុងនោះបច្ចេកទេសអនុវត្តរួមមាន :

- **បច្ចេកទេសចិញ្ចឹមមាន់** : ក្នុងផ្តោតលើចំនុចសំខាន់ៗដូចជាការជ្រើសរើសទីតាំងសំរាប់ធ្វើទ្រុង ការជ្រើសរើសពូជមាន់ដែល មានជើង ពិណលឿង ការផ្តល់ចំណីនិងទឹក ការធ្វើថ្នាំបន្តក់មាន់។
- **វិធីធ្វើមេជីសំរាប់អោយចេញផ្កា-ផ្លែ :** យកសំបកលាស ខ្យង ខ្ចៅ មកលីងអោយឡើងពិណគ្នោត ចាស់ហើយយកមកត្រាំជាមួយទឹកខ្មេះរយៈពេល ២០-២៥ថ្ងៃ។

- **វិធីធ្វើជីសរីរាង្គបំប៉នផ្លែអោយធំល្អ :** យកផ្លែល្ហុងទុំ ផ្លែល្ពៅទុំ ចេកទុំ សេដាទុំ ស្វាយទុំ ម្នាស់ មកចិញ្រ្ចាំបញ្ចូលគ្នារួចយកទៅត្រាំក្នុងថាប់ រឺពាងដែលមានចំណុះ ២០លីត្រ ដាក់មេស្ករអំពៅ១/៤ លីត្រ មេជីអ៊ីអ៊ិចអឹម ១/៤លីត្រ រឺ មេជីអ៊ីអឹម ត្រាំរយៈពេល ១០-១៥ ថ្ងៃ អាចប្រើប្រាស់បាន។

- **បច្ចេកទេសចិញ្ចឹមត្រី** : ជ្រើសរើសទីតាំងជីកស្រះ ការដាក់ជីស្រស់ដើម្បីបង្កើតប្លង់តុង ការការពារកុំអោយត្រីពុលនៅពេលមានភ្លៀងខ្លាំង ការជ្រើសរើសពូជ ថែទាំ ផ្តល់ចំណី និង ការប្រមូលផល។

- **បច្ចេកទេសធ្វើថ្នាំពុលធម្មជាតិបណ្តេញសត្វល្អិតចង្រៃរួមមាន** : យករុក្ខជាតិដែលមានជាតិល្វីង ហិរ និង រុក្ខជាតិមានជាតិពុល រួចយករុក្ខជាតិទាំងនោះ មកចិញ្រ្ចាំបញ្ចាលគ្នា ដាក់ត្រាំក្នុងធុង រឺ ពាង រយៈពេល ១៥-៣០ថ្ងៃ ទើបអាចប្រើប្រាស់បាន។

- **វិធីធ្វើមេជីកំប៉ុស្តិ៍ទឹក** : យកស្លឹករុក្ខជាតិបៃតងដែលឆាប់រលួយមកចិញ្រ្ចាំបញ្ចូលគ្នា ដាក់អំបិល ស្ករត្នោត ទឹកនោមគោ ក្របី និង មនុស្ស ដាក់បញ្ចូលគ្នាក្នុងធុង រឺ ពាង ដែលមានចំណុះតាមលទ្ធភាពដែលកសិករអាច រកបាន ត្រាំទុករយៈពេល ១៥- ២០ថ្ងៃ អាចប្រើប្រាស់បាន។

- វិធីបន្សុតជីកំប៉ុស្តិ៍ឱ្យក្លាយជាជីប្រភេទលេខ ១ : ត្រូវយក ជីលាមកគោ ៥០គីឡូក្រាម( គ.ក្រ) ម្សៅត្រីកិន ០.៥គ.ក្រ, មេជីអ៊ីអឹម ១លីត្រ អង្កាមស្រស់ ២០ គ.ក អង្កាមដុត ៣០ គ.ក លាយជាមួយឆ្អឹងគោដុត ១ គ.ក រួចយកវត្ថុធាតុខាងលើមក លាយច្របល់ឱ្យសព្វ រួចយកមេជីអ៊ីអឹមលាយជាមួយទឹកធម្មតា ១០- ១៥ លីត ដាក់ក្នុង ធុងផ្កាឈូកស្រោចច្របល់ឱ្យសើមល្មម រួចវាស កំរាស់មួយតឹក ហើយគ្រប់ស្លឹកផ្អាប់ទុកក្នុងម្លប់ក្នុងរយៈពេល ២ថ្ងៃ ទើបបើកមើល បើឃើញមានផ្សិតស្បែក្រាលនៅលើជីហើយ យើងប្របល់ម្តងទៀត បន្ទាប់មកស្រោចមេជីឱ្យសើម ល្មម ទើបគ្របទុករយៈពេល ២ថ្ងៃទៀត រួចសំដិលហាលក្នុងម្លប់រយៈពេល ១ថ្ងៃ ទើបច្រកការ៉ុងទុកប្រើប្រាស់។ ហើយ វិធីប្រើប្រាស់ជីស្រែ ១ ហ.ត ត្រូវប្រើប្រាស់ជីបន្សុតទំងន់ ១ តោន លើដំណាំស្រូវ រឺឯចំពោះប្រភេទដំណាំបន្លែផ្សេងៗ អាចប្រើប្រាស់តាមទំលាប់ធម្មតាដែលកសិករធ្លាប់អនុវត្ត។

នៅមុនពេលបញ្ចប់វគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលបាន ជំរុញ និង លើកទឹកចិត្តដល់ក្រុមកិសករយកបច្ចេកទេស និង ប្រើប្រាស់ចំណេះដឹងទាំងនេះ អនុវត្តលើកសិដ្ឋានរបស់ខ្លួន ដើម្បីប្រែក្លាយទ្រឹស្តី បទពិសោធន៏ជោគជ័យទាំងនេះ ឱ្យទៅជាលទ្ធផលជាក់ស្តែង។





ស្វាយរៀង, ថ្ងៃទី ១០ កក្កដា ២០១១

**មាឃ មករា**

**បុគ្គលិកកម្មវិធីស្បៀងអាហារ**